# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា
(IBEC) Project

ខែ កញ្ញា ឆ្នាំ ២០១៣

លេខ ១៥

## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### ទិដ្ឋភាពរួមរបស់ IBEC

- ឯ.ឧ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ ចូលរួមក្នុងពិធីចែកវិញ្ញាបនបត្រ
- នាយិកាបេសកកម្ម USAID និងអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ទស្សនកិច្ចសាលារៀនដែលគាំទ្រដោយគម្រោង IBEC ក្នុងខេត្តកំពង់ចាម
- គណៈគ្រប់គ្រងសាលារៀនចំនួន៥៥៣នាក់ ទទួលបានវិញ្ញាបនបត្រស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន

### ដៃគូគម្រោង IBEC

- គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

គម្រោងត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោក ដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។

- ដៃគូក្នុងស្រុកផ្សេងទៀត មានអង្គការ ៖ WCRD, BSDA, NEP, EDA និង Media One

## ពិធីចែកវិញ្ញាបនបត្រស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន



*ឯ.ឧ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ លោកអភិបាលរងខេត្តកំពង់ចាម និងតំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ចូលរួមក្នុងពិធីចែកវិញ្ញាបនបត្រ*

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ IBEC បានប្រារព្ធពិធីចែកវិញ្ញាបនបត្រស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀននៅសាលាគរុកោសល្យ និងវិក្រិតការខេត្តកំពង់ចាម ដល់គណៈគ្រប់គ្រងសាលារៀនដែលបានបញ្ចប់វគ្គបំប៉នរបស់ IBEC ក្រោមអធិបតីភាពរបស់ ឯ.ឧ ណាត ប៊ុនរឿន និងមានការចូលរួមពីអភិបាលរងខេត្តកំពង់ចាម តំណាង USAID មន្ទីរអប់រំខេត្ត បុគ្គលិកអង្គការអប់រំពិភពលោក និងអង្គការខេប ។

IBEC បានបើកវគ្គបំប៉នស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀនចាប់តាំងពីឆ្នាំ ២០១០មក បេក្ខជនដែលបានបញ្ចប់វគ្គដោយជោគជ័យត្រូវបានទទួលវិញ្ញាបនបត្រក្នុងត្រីមាសនេះ ។ នាយក និងនាយករងមកពីសាលារៀនជិត៣០០សាលាក្នុងខេត្តគោលដៅទាំងបីមាន ខេត្តកំពង់ចាម សៀមរាប និងក្រចេះ ដែលត្រូវទទួលបានវិញ្ញាបនបត្រនេះ ។

ជារួមមាននាយក និងនាយករងសាលារៀនដែលបញ្ចប់វគ្គហើយទទួលបានវិញ្ញាបនបត្រមានចំនួន ៥៥៣ នាក់ ។ នៅពេលដែលធ្វើការបង្ហាញពីសមាសភាពអ្នកចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នេះ រដ្ឋលេខាធិការក្រសួងអប់រំមានការស្ញើចសរសើរយ៉ាងខ្លាំងចំពោះការសម្រេចបានរបស់ IBEC ក្នុងការគាំទ្រអនុវត្តនូវគោលនយោបាយ របស់ក្រសួងអប់រំ ជាពិសេសការផ្តល់វគ្គបំប៉នដ៏សំខាន់នេះដល់គណៈគ្រប់គ្រងសាលារៀន ។

ឯកឧត្តមបានសង្កត់ធ្ងន់ថា "សាលារៀនអាចល្អទៅបានលុះត្រាតែមាននាយកសាលាល្អ" ហើយឯកឧត្តមក៏បានសំណូមពរដល់ IBEC គួរតែបន្តប្រឹងប្រែងធ្វើការងារដ៏ល្អនេះក្នុងតំបន់នេះជាបន្តទៀត ៕

*ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។*
*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*
*ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤* E-mail: worldedcam@worlded.org.kh

## សមាសភាគ១៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

ក្នុងត្រីមាសនេះសមាសភាគនេះបានផ្តោតសំខាន់លើការបន្តយកចិត្តទុកដាក់គាំទ្រដល់ក្រុមប្រឹក្សាឃុំដើម្បីផ្លាស់ប្តូរទម្លាប់ស្ថាប័នគាំទ្រមួយនេះក្នុងការជួយគាំទ្រដល់សាលារៀនរបស់ពួកគាត់ដែលធ្លាប់ទទួលបានជំនួយពី IBEC ។ ចំណុចដែលផ្តោតសំខាន់ក្នុងការផ្លាស់ប្តូរមួយនេះគឺការផ្តល់មូលនិធិពីក្រុមប្រឹក្សាឃុំ ឬ CEFACs ដោយមានទុនបដិភាគពីគម្រោង ។ សកម្មភាពទាំងនេះបានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងផែនការនិរន្តរភាពរបស់សាលារៀនដែលបានធ្វើពីដំបូងមក ។

បច្ចុប្បន្នមានឃុំចំនួន១២ក្នុងចំណោម១៦បានផ្តល់ទុនបដិភាគដល់សាលារៀនជុំទី១ ដែលជាសាលារៀនធ្លាប់បានជួយគាំទ្រពី IBEC ។ ទុនបដិភាគទាំងនោះសរុបមានចំនួន $៨,៧៥៧.00 ប្រហែលជា ៩១% នៃទុនបដិភាគសរុបប្រចាំឆ្នាំ ($៩,៦៥២.00) ។



*ការបង្កើតទម្លាប់នៃស្ថាប័នគាំទ្រដល់សាលារៀនក្នុងសហគមន៍ ៖ កិច្ចប្រជុំរបស់គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នា (CEFAC) ក្នុងឃុំអំពីលតាពក កំពង់ចាម*



*ការអង្កេតសកម្មភាពសិក្សារបស់សិស្ស៖ ឯ.ឧ សំ សេរីរត៍ និងនាយិកាបេសកកម្ម USAID សង្កេតលើមុខវិជ្ជាវិទ្យាសាស្ត្រ ក្នុងបន្ទប់ពិសោធន៍ដែលគម្រោងគាំទ្រ ក្នុងខេត្តកំពង់ចាម*

ក្នុងត្រីមាសនេះ ជំនួសឱ្យការប្រជុំប្រចាំខែនៅឯអគ្គនាយកដ្ឋានអប់រំក្នុងទីក្រុងភ្នំពេញ ឯ.ឧ សំ សេរីរត៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់របស់ IBEC បានដឹកនាំគណៈប្រតិភូក្រុមពិគ្រោះយោបល់ដើម្បីធ្វើទស្សនកិច្ចសាលារៀនគោលដៅរបស់ IBEC ដើម្បីសង្កេតមើលការអនុវត្តរបស់គម្រោង និងទទួលនូវព័ត៌មានត្រឡប់ពីគ្រប់អ្នកពាក់ព័ន្ធ ។

គណៈប្រតិភូដែលមានតំណាងមកពីនាយកដ្ឋានចំនួន៦នៃក្រសួងអប់រំរួមមាន នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សា នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងការិយាល័យ ICT ។ នាយិកាបេសកកម្ម USAID ដែលទើបតែមកដល់ប្រទេសកម្ពុជាថ្មីៗនេះ និងមានចំណាប់អារម្មណ៍ក្នុងការសិក្សាស្វែងយល់បន្ថែមអំពីកម្មវិធីអប់រំក៏បានចូលរួមក្នុងគណៈប្រតិភូនេះដែរ ។

គណៈប្រតិភូជាន់ខ្ពស់នេះបានធ្វើទស្សនកិច្ចទៅកាន់សាលាមធ្យមសិក្សាចំនួន២ និងបឋមសិក្សាចំនួន១ក្នុងខេត្តកំពង់ចាមមានអនុវិទ្យាល័យអនុវត្ត វិទ្យាល័យ ប៉ើសពី និងបឋមសិក្សាជៀស ។ អំឡុងពេលទស្សនកិច្ច គណៈប្រតិភូមានឱកាសស្តាប់របាយការណ៍ពីនាយកសាលា ពីមន្ទីរអប់រំខេត្ត និងធ្វើការសន្ទនាជាមួយសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូដើម្បីទទួលបាននូវព័ត៌មានពីសកម្មភាពរបស់គម្រោង ។

ការបន្តគាំទ្រការកសាងសមត្ថភាពដល់សាលារៀនបំភ្លឺផ្លូវ គឺជាសកម្មភាពសំខាន់សម្រាប់សមាសភាគនេះ ជាពិសេសអន្តរាគមន៍នេះចាត់ទុកថាជាសកម្មភាពដ៏សំខាន់សម្រាប់យុទ្ធសាស្ត្រចាកចេញក្នុងឆ្នាំទី៥នេះ ។

ក្នុងត្រីមាសនេះ សមាសភាគនេះបានធ្វើការជាមួយក្រុមការងារថ្នាក់ខេត្ត (PWG) ដើម្បីរៀបចំដំណើរទស្សនកិច្ចទៅកាន់សាលារៀនបំភ្លឺផ្លូវចំនួន២០ ដែលមានអ្នកចូលរួមចំនួន២៨៤នាក់ (ស្ត្រី ១១៤នាក់)មកពីសាលារៀនជុំវិញចំនួន៤២ ។

## សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

### កម្មវិធីអាហារូបករណ៍



*សិស្សអាហារូបករណ៍របស់ IBEC ធ្វើដំណើរទៅសាលារៀនរបស់ពួកគេដោយជិះកង់ដែលទទួលបានពីគម្រោង*

សមាសភាគនេះបានបញ្ចប់ការធ្វើបញ្ជីអត្រាគង់វង់ក្នុងចំណោមសិស្សអាហារូបករណ៍បឋមសិក្សា និងមធ្យមសិក្សា ។ ជាចុងក្រោយស្ថិតិបានបង្ហាញថាអត្រាគង់វង្សនៅមានកម្រិតខ្ពស់គឺ ៩៧% នៅបឋមសិក្សា និង៩៦% នៅមធ្យមសិក្សា ។ អត្រាគង់វង្សនេះមានចំនួនកុមារា និងកុមារីប្រហាក់ប្រហែលគ្នា ។ អ្នកតាមដានការសិក្សាបានបង្ហាញថាមូលហេតុនៃសេដ្ឋកិច្ចនៅតែជាកត្តាចម្បងក្នុងការបោះបង់ការសិក្សាទាំងនៅបឋមសិក្សា និងមធ្យមសិក្សា ។ ករណីបោះបង់ការសិក្សាដោយសារបញ្ហាសេដ្ឋកិច្ចមានចំនួន ៦៣% នៅបឋមសិក្សា និងចំនួន ៧០% នៅមធ្យមសិក្សា ។ ចំណុចខុសគ្នាសំខាន់ក្នុងរបាយការណ៍ត្រីមាសមុនគឺកុមារភាគច្រើនមិនបោះបង់ចោលសាលារៀនរយៈពេលយូរដោយសារមូលហេតុធ្វើការងារក្នុងតំបន់ពួកគេរស់នៅនោះទេ ប៉ុន្តែគឺដោយសារការធ្វើចំណាកស្រុកទៅតំបន់ឆ្ងាយដើម្បីស្វែងរកការងារធ្វើដូចជាទៅទីក្រុងភ្នំពេញ ក្រុងប៉ោយប៉ែត ក្រុងសៀមរាប និងផ្សេងទៀតទៅប្រទេសថៃ ។

អំឡុងពេលត្រីមាសនេះ IBEC បានបើកប្រាក់ឧបត្ថម្ភចុងក្រោយដល់គរុសិស្សចំនួន ១២០នាក់ ដែលបានជ្រើសរើសពីឃុំដាច់ស្រយាលក្នុងការដោះស្រាយបញ្ហាខ្វះគ្រូ ។ ប្រាក់ឧបត្ថម្ភប្រចាំត្រីមាសចំនួន $៦០ ឬស្មើនឹង $៧,២០០ សម្រាប់សាលាគរុកោសល្យទាំង៣ ។ ទាំងនេះជាការធ្វើឱ្យសិស្សទាំងអស់អាចបន្តការសិក្សាដែលពួកគេបានចូលរៀននៅសាលាគរុកោសល្យកាលពីឆ្នាំមុននឹងត្រូវបញ្ចប់ការសិក្សាក្នុងខែ សីហា ឆ្នាំ២០១៣ ។ នេះជាក្រុមគរុសិស្សដែលទទួលអាហារូបករណ៍ពី IBEC លើកចុងក្រោយដោយហេតុថា USAID មិនមានអន្តរាគមន៍នេះទៀតទេ ។ សរុបទាំងអស់ IBEC បានជួយគាំទ្រអាហារូបករណ៍ដល់គរុសិស្សចំនួន ៣៦០នាក់ក្នុងចុងឆ្នាំទី៤នេះ ។ IBEC កំពុងព្យាយាមពិចារណាសិក្សាលើអន្តរាគមន៍នេះក្នុងឆ្នាំទី៥ ដើម្បីកំណត់នូវប្រសិទ្ធភាពរបស់វា និងផលប៉ះពាល់ទាំងមូល ៕

## កញ្ចប់អំណោយសាលារៀនដែលដឹកនាំដោយអ្នកពាក់ព័ន្ធ

សាលារៀនបានបន្តបង្ហាញនូវភស្តុតាងបទពិសោធន៍ដ៏សន្ធឹកសន្ធាប់ក្នុងការធ្វើឱ្យឯកទេសសេវាអប់រំដំណើរការកើនឡើងដូចជា បង្កើតបណ្ណាល័យ បណ្ដាញកុមារជួយកុមារ ក្រុមប្រឹក្សាកុមារ ដែលធ្វើឱ្យសមាសភាគនេះដើរតួជាអ្នកតាមដានញឹកញាប់នៅក្នុងដំណាក់កាលចុងក្រោយនៃការអនុវត្តរបស់គម្រោង ។ ក្រុមសមាសភាគនេះបានចំណាយពេលដ៏ច្រើនក្នុងការធ្វើសកម្មភាព និងកត់ត្រាលទ្ធផលដែលក្នុងករណីនេះសមាសភាគនេះបានរាយការណ៍ថាក្នុងចំណោមក្រុមប្រឹក្សាកុមារចំនួនបីទៅបួនក្រុមបានសម្ដែងថាពួកគេពេញចិត្តលើសកម្មភាពទាំងនេះ ។

សមាសភាគនេះផ្ទាល់បានជួយវាយតម្លៃដោយមន្ត្រីកម្មវិធីថ្នាក់ស្រុកនៅក្នុងខេត្តទាំងបី ។ ការវាយតម្លៃផ្ដោតលើលក្ខណៈវិនិច្ឆ័យដែលរួមមាន លទ្ធភាពក្នុងការបង្កើតផែនការប្រសិទ្ធភាព បង្កើតថវិកា និងកាលវិភាគ និងកម្រិតនៃការដឹកនាំក្រុមប្រឹក្សាកុមារដោយសិស្ស (ជាជាងដឹកនាំដោយនាយកសាលា) ។

IBEC ក៏កំពុងបន្តផ្ដល់ថវិការគាំទ្រដល់គ្រូជំនួយពីរភាសាទៅតាមសំណើរបស់សាលារៀនគោលដៅក្នុងផែនការប្រចាំឆ្នាំរបស់ពួកគេ ។ សេវាកម្មនេះ ផ្ដោតចម្បងទៅលើសាលារៀនគោលដៅដែលមានចំនួនជនជាតិចាមភាគច្រើន និងកូនៗរបស់ពួកគេមករៀនក្នុងសាលាហើយចេះភាសាខ្មែរតិចតួច ។

នៅចុងត្រីមាសនេះសមាសភាគនេះធ្វើបញ្ជីចំនួនសិស្សចូលអានក្នុងបណ្ណាល័យគ្រប់បណ្ណាល័យតាមសាលារៀននីមួយៗ ។ នៅបឋមសិក្សាមន្ត្រីតាមមូលដ្ឋានបានរាយការណ៍ថាមានសិស្សចូលអានកើនឡើងសរុបចំនួន ១២៧,០៧៦នាក់ ខណៈពេលដែលនៅមធ្យមសិក្សាមានចំនួន ៨១,៥៣៩នាក់ រួមទាំងការកើនឡើងរបស់គ្រូចូលបណ្ណាល័យ ប៉ុន្តែមានការកើនឡើងតិចតួចចំពោះសហគមន៍ ។

### ក្ដីស្រមៃ និងការជួយគាំទ្រពី USAID

ជោត ស្រីដែន ជាសិស្សរៀនថ្នាក់ទី៩នៅអនុវិទ្យាល័យសង្កើប ។ នាងមានដើមកំណើតនៅខេត្តរតនៈគីរី ហើយនាងផ្លាស់ទីលំនៅមករស់នៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាមពីរទៅបីឆ្នាំមកហើយ ។ ឪពុករបស់នាងសង្ឃឹមថា ខេត្តកំពង់ចាមអាចឱ្យកូនរបស់គាត់ងាយស្រួលចូលរៀនបាន ។ ម្ដាយរបស់ស្រីដែនបានស្លាប់ច្រើនឆ្នាំទៅហើយដូច្នេះគ្រួសារទាំងមូលពឹងផ្អែកតែទៅលើឪពុកនាងតែម្នាក់គត់ ។ គ្រួសាររបស់នាងមានសមាជិកចំនួន៥នាក់រួមទាំងបងប្រុស និងបងស្រីរបស់នាងដែលធ្វើជាកម្មករនៅខេត្តរតនៈគីរីជាមួយឪពុករបស់នាង ។ ប្អូនប្រុសរបស់នាងមានអាយុ១៤ឆ្នាំហើយក៏ជាព្រះសង្ឃក្នុងវត្តជិតនោះដែរ ។ នាងគឺជាកូនតែម្នាក់គត់ក្នុងគ្រួសារដែលកំពុងសិក្សា ។ ស្រីដែនមានក្ដីស្រមៃចង់បញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ និងរកការងារល្អធ្វើ ដូច្នេះនាងអាចជួយឧបត្ថម្ភគ្រួសាររបស់នាង ។ នាងធ្លាប់បានប្រាប់ឪពុករបស់នាងថានាងនឹងសម្រេចឱ្យបាននូវក្ដីស្រមៃនេះដើម្បីទទួលបានការងារល្អដែលអាចជួយឧបត្ថម្ភគ្រួសារឱ្យបានល្អ ។ អ្នកជិតខាងរបស់នាងចំនួនពីរនាក់ហើយដែលចង់រៀបការជាមួយនាងប៉ុន្តែត្រូវបាននាងបដិសេធព្រោះនាងចង់បញ្ចប់ការសិក្សារបស់នាង ។ នាងសង្ឃឹមថានាងនឹងរៀបការនៅពេលក្រោយប្រសិនបើនាងអាចរកបានមនុស្សល្អម្នាក់ ប៉ុន្តែក្នុងពេលឥឡូវនាងមានអារម្មណ៍ថានាងនៅក្មេងពេកក្នុងការរៀបការ ។

គ្រួសាររបស់ស្រីដែនមិនមានដីនោះទេ ប៉ុន្តែម្ដាយមីងរបស់នាងបានអនុញ្ញាតឱ្យនាងសង់ផ្ទះប្រក់ស្លឹកត្នោតតូចមួយលើដីរបស់គាត់ ។ ប៉ុន្តែស្រីដែននិយាយថានាងមិនហ៊ាននៅផ្ទះនោះតែម្នាក់ឯងនោះទេនៅពេលដែលឪពុករបស់នាងមិននៅ ដូច្នេះនាងស្នាក់នៅជាមួយម្ដាយមីងនាងជំនួស ។

ស្រីដែនជាសិស្សឧស្សាហ៍ នាងមិនដែលឈប់ពីការសិក្សានោះទេលើកលែងតែពេលនាងមានជម្ងឺ ។ នាងទទួលបានពិន្ទុខ្ពស់រៀងរាល់ត្រីមាសស្ទើរគ្រប់មុខវិជ្ជា នាងក៏មានចំណាប់អារម្មណ៍សិក្សាភាសាចិននៅក្នុងវិហារចិនជិតផ្ទះរបស់នាងផងដែរ ។ ជាទូទៅនាងស្នាក់នៅជាមួយម្ដាយមីងរបស់នាងនៅពេលដែលឪពុករបស់នាងធ្វើការនៅរតនៈគីរី រឺក៏ពេលខ្លះស្នាក់នៅជាមួយមិត្តភ័ក្ដិដើម្បីសិក្សាត្រៀមប្រឡង ។ ដោយមានការជួយគាំទ្រពី USAID នាងទទួលបានសម្ភារៈសម្រាប់ការសិក្សា និងការឧបត្ថម្ភសម្រាប់រៀនក្រៅម៉ោង ដែលជាកត្តាចាំបាច់សម្រាប់នាងដើម្បីប្រឡងឱ្យជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិក្នុងឆ្នាំនេះ ។ ស្រីដែនក៏បានព្យាយាមរកប្រាប់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដោយស៊ីឈ្នួលលាងចាន និងបោកសំលៀកបំពាក់ឱ្យអ្នកជិតខាងរបស់នាងដោយទទួលបានប្រាក់ពី ៧,០០០រៀន ៨,០០០រៀលក្នុងមួយសប្ដាហ៍ ។



*ស្រីដែនធ្វើដំណើរត្រឡប់ពីរៀនថ្នាក់ក្រៅម៉ោងដែលរៀបចំដោយ IBEC (រូបភាពខាងឆ្វេង)*

## សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍



***ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់ការអាន*** *៖ មាតាបិតាសិស្សមកសាលារៀនដើម្បីអានសៀវភៅជាមួយកូនរបស់ពួកគេ*

ការងាររបស់សមាសភាគ៣ក្នុងត្រីមាសនេះផ្ដោតសំខាន់លើសកម្មភាពពីរ ទី១គឺបន្តសកម្មភាពពង្រឹងសមត្ថភាពដល់គណៈកម្មការទ្រទ្រង់សាលាដើម្បីលើកកម្ពស់ការអានក្នុងសាលារៀនរបស់ពួកគាត់ ទី២គឺបញ្ចប់វគ្គបំប៉នភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀនដែលបានធ្វើចាប់តាំងពីដំបូងមក ។

អំឡុងពេលធ្វើរបាយការណ៍ សមាសភាគនេះ និងមន្ត្រីបច្ចេកទេសថ្នាក់ស្រុកបានធ្វើការវាយតម្លៃនៅតាមមូលដ្ឋានដើម្បីកំណត់ថាតើគណៈកម្មការទ្រទ្រង់សាលាបានអនុវត្តតាមគោលការទាំង៦ក្នុងការលើកកម្ពស់ការអានដែររឺទេ ។ សាលារៀនសរុបចំនួន ១២៦ ត្រូវបានធ្វើការវាយតម្លៃនេះ ហើយសាលារៀនភាគច្រើនជាសាលារៀនក្នុងជុំទី១ ។ នៅចុងឆ្នាំ ២០១២សមាសភាគនេះបានធ្វើការតម្រង់ទិសដល់មន្ត្រីសម្របសម្រួលខេត្ត និងមន្ត្រីបច្ចេកទេសថ្នាក់ស្រុកពាក់ព័ន្ធក្នុងការរៀបចំធ្វើសិក្ខាសាលាក្នុងគោលបំណងពង្រឹងដល់តួនាទីរបស់គណៈកម្មការទ្រទ្រង់សាលាដើម្បីលើកកម្ពស់ការអានក្នុងតំបន់របស់ពួកគាត់ ។ គោលបំណងនៃការងារនេះគឺដើម្បីជួយដល់គណៈកម្មការទ្រទ្រង់សាលាឱ្យមានការឆ្លើយតបប្រសើរទៅលើការលើកកម្ពស់គុណភាពអប់រំនៅក្នុងសាលារៀនរបស់ពួកគាត់ ជាពិសេសពាក់ព័ន្ធទៅនឹងជំនាញអានដែលជាកម្មវិធីលេចធ្លោរបស់ក្រសួងអប់រំក្នុងឆ្នាំថ្មីៗនេះ ។ នេះជាផែនការប្រជុំលើកទី៣ជាមួយក្រុមការងារថ្នាក់ខេត្តដើម្បីធ្វើការជាមួយគណៈកម្មការទ្រទ្រង់សាលានៅក្នុងតំបន់នេះ ៕

## សមាសភាគ៤៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

*ការអប់រំបំណិនជីវិត ៖* ក្នុងត្រីមាសនេះ ក្រុមការងារបំណិនជីវិតបានធ្វើការវាយតម្លៃលើការអនុវត្តសកម្មភាពអប់រំបំណិនជីវិតនៅតាមសាលារៀន ។ ក្នុងករណីនេះគម្រោងបានបែងចែកសម្ភារៈបង្រៀន និងរៀនខុសៗគ្នាចំនួន៦,៤៧៧តាមសាលារៀនគោលដៅក្នុងខេត្តទាំង៦ ។ ក្រុមអ្នកវាយតម្លៃរួមមានបុគ្គលិកគម្រោង មន្ទីរអប់រំខេត្ត និងមន្ត្រីក្រសួងអប់រំបានចូលរួមក្នុងការវាយតម្លៃក្នុងខែមិថុនា ឆ្នាំ២០១៣ដោយផ្អែកលើប៉ារ៉ាម៉ែត្រចំនួន៣គឺ (i) វិធី សាស្ត្របង្រៀនរបស់គ្រូ (ii) សមត្ថភាពរបស់សិស្ស និង(iii) ប្រសិទ្ធភាពប្រតិបត្តិការលើស្ថាប័នសាលារៀន ។ ការវាយតម្លៃនេះបានបញ្ចប់ក្នុងត្រីមាសនេះដោយមានការយកចិត្តទុកដាក់ពីក្រសួងអប់រំ និងបានរកឃើញថា ៨០% នៃគ្រូដែលបានអង្កេតទទួលបានពិន្ទុគួរឱ្យពេញចិត្ត ។ ការវាយតម្លៃស្របពេលគ្នានេះដែរទៅលើសាលារៀនថ្មីចំនួន២៥ក្នុងខេត្តកំពង់ធំ ស្វាយរៀង និងព្រៃវែងក៏បានរកឃើញប្រហាក់ប្រហែលគ្នាដែរដោយមានសាលារៀនចំនួន ៩២% បានអនុវត្តកម្មវិធីបំណិនជីវិតស្របទៅនឹងយុទ្ធសាស្ត្រណែនាំ ។

សមាសភាគនេះក៏បានរាយការណ៍ដែរថាសៀវភៅបំណិនជីវិតចំនួន១២ប្រភេទត្រូវបានអនុម័តិដោយគណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សានៃក្រសួងអប់រំដោយ១៨ប្រភេទផ្សេងទៀតមិនទាន់បានអនុមតិនៅឡើយ ។

ក្នុងត្រីមាសនេះដែរសមាសភាគនេះក៏បានធ្វើការតាមដានអនុវិទ្យាល័យទាំង១៧ដែលទទួលបានកម្មវិធីបំណិនជីវិតរកប្រាក់ចំណូលក្នុងឆ្នាំទី២ និងទី៣ ។ នេះជាកញ្ចប់ថវិកាដើម្បីធ្វើការពិសោធន៍ក្នុងគោលបំណងជួយសាលារៀនដើម្បីបង្វែរសកម្មភាពអប់រំបំណិនជីវិតរបស់សិស្សនៅក្នុងសាលារៀនរបស់ពួកគេឱ្យទៅជាសកម្មភាពរកប្រាក់ចំណូលដែលនឹងអាចធ្វើឱ្យសកម្មភាពរបស់គម្រោងមាននិរន្តរភាពទៅថ្ងៃអនាគត ។ ថវិកាចំនួន $៦,៦៨៣ ត្រូវបានចំណាយសម្រាប់គោលបំណងនេះកាលពីឆ្នាំទី២ ។ សកម្មភាពនេះមានសារសំខាន់ក្នុងការបង្កើតសហគ្រាសរកប្រាក់ចំណូលដោយផ្សារភ្ជាប់ជាមួយកម្មវិធីបំណិនជីវិត ។

*ការបណ្តុះបណ្តាលគ្រូ ៖* សមាសភាគនេះបានចំណាយពេលដ៏ច្រើននៃត្រីមាសក្នុងការរៀបចំថ្នាក់រៀនសម្រាប់របាយការណ៍ប្រចាំឆ្នាំ ។ សកម្មភាពទាំងនេះតម្រូវឱ្យមានការអង្កេតរាប់រយថ្នាក់រៀន ការធ្វើតេស្តសិស្សលើការអាន និងសរសេរ និង ការអង្កេតទៅលើការប្រើប្រាស់បន្ទប់ពិសោធន៍ ។

សមាសភាគនេះក៏បានធ្វើការអង្កេតទៅលើក្លឹបមុខវិជ្ជា ថាតើពួកគេបាននឹងកំពុងអនុវត្តបានកម្រិតណា ។



***ដំណើរការដោយត្រង់លើគុណភាពបង្រៀន៖*** *គ្រូកុមារមេត្រីមធ្យមសិក្សាសម្របសម្រួលការងារក្រុម ក្នុងខេត្តកំពង់ចាម*

*ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន ៖* ក្រុមការងារ ICT បានរាយការណ៍ថាសកម្មភាពរៀបចំបន្ទប់កុំព្យូទ័រថ្មី និងការបំប៉នគ្រូត្រូវបានបញ្ចប់ចាប់តាំងពីត្រីមាសមុនមកម្ល៉េះ ។ ក្នុងន័យនេះបន្ទប់កុំព្យូទ័រថ្មីចំនួន២ត្រូវបានរៀបចំក្នុងឆ្នាំទី៤នេះ ។ សរុបមកមានបន្ទប់កុំព្យូទ័រចំនួន២៥ហើយចាប់តាំងពីគម្រោងបានចាប់ផ្តើមមក ។ ក្នុងត្រីមាសនេះក្រុមការងារ ICT បានផ្តោតលើការរៀបចំពិព័រណ៌ការងារគម្រោង និងក្លឹបមុខវិជ្ជាក្នុងខេត្តគោលដៅទាំងបីដើម្បីផ្តល់វេទិកាដល់សិស្សក្នុងការធ្វើបទបង្ហាញការងារគម្រោង និងចែករំលែកគំនិតគ្នាទៅវិញទៅមក ។

ក្រុមការងារក៏បានធ្វើការអង្កេតតវិយាបថសិស្សចំនួន ៤១១នាក់នៅតាមសាលារៀនចំនួន២០ដើម្បីកំណត់ចំនួនសិស្សដែលទទួលបានការសិក្សា ICT ។ លទ្ធផលនៃការអង្កេតបានបង្ហាញភាពវិជ្ជមានដោយមានសិស្សចំនួន ៦៥%រាយការណ៍ថាពួកគេចូលចិត្តយ៉ាងខ្លាំងទៅលើគុណភាពអប់រំ ICT ដែលពួកគេទទួលបានក្នុងឆ្នាំនេះ និងការសិក្សា ICT បានធ្វើឱ្យពួកគេសម្រេចចិត្តបន្តការសិក្សាទៅមុខទៀត ។

ដូចបានរៀបរាប់ខាងលើ សមាសភាគនេះបានរៀបចំឱ្យមានពិព័រណ៌ការងារគម្រោង និងក្លឹបមុខវិជ្ជាក្នុងខេត្តគោលដៅទាំងបីរួមមានខេត្តក្រចេះធ្វើនៅថ្ងៃទី ៣ ខែមិថុនា ខេត្តកំពង់ចាមធ្វើនៅថ្ងៃទី ៥ មិថុនា និងខេត្តសៀមរាបធ្វើនៅថ្ងៃទី ៧ មិថុនា ។ នេះជាឆ្នាំទី៥ហើយដែលគម្រោងបានរៀបចំពិព័រណ៍នេះ ហើយពិព័រណ៍នេះបានក្លាយទៅជាព្រឹត្តិការណ៍ដែលធ្វើឱ្យសាលារៀន និងសិស្សានុសិស្សមានចិត្តចង់ចូលរួមជាខ្លាំង (ពិព័រណ៍លើកទី១ធ្វើនៅក្នុងឆ្នាំ២០០៩ក្រោមគម្រោងសាលារៀនដើម្បីជីវិត) ។ ព្រឹត្តិការណ៍នេះជាវេទិកាប្រគួតប្រជែងស្នាដៃស្រាវជ្រាវរបស់សិស្សរយៈពេលមួយឆ្នាំ និងតាំងបង្ហាញសកម្មភាពផ្សេងៗដែលរៀបរៀងឡើងដោយសិស្សមកពីសាលារៀនគោលដៅចំនួន៤២ដែលទទួលបានបន្ទប់កុំព្យូទ័រ ឬបន្ទប់ពិសោធន៍ ។ ការធ្វើបទបង្ហាញនេះបានបញ្ជាក់នូវការចូលរួមយ៉ាងជ្រាលជ្រៅរបស់សិស្សជាមួយគម្រោងដែលមានប្រធានបទទាក់ទង នឹងសហគមន៍របស់ពួកគេ ។ ពិព័រណ៍ឆ្នាំនេះបានរាយការណ៍ថាមានការចូលរួមពីសិស្សានុសិស្សចំនួន៥៤៣នាក់ និងមានប្រធានបទបង្ហាញចំនួន២១២ រួមមាន អំពើហឹង្សាក្នុងគ្រួសារ ជំនាញទីផ្សារ បរិស្ថាន ប្រវត្តិសាស្ត្រសហគមន៍ គ្រោះថ្នាក់ចរាចរណ៍ និងការពិសោធន៍វិទ្យាសាស្ត្រដ៏គួរឱ្យចាប់អារម្មណ៍ដែលបង្ហាញដោយសិស្ស ៕









***ឧទាហរណ៍ដ៏អស្ចារ្យក្នុងការផ្តល់សិទ្ធិដល់យុវជន ៖*** *សិស្សានុសិស្សសម្តែងរបាំប្រពៃណី ធ្វើបទបង្ហាញលើប្រធានបទដែលពួកគេចាប់អារម្មណ៍ និងបង្ហាញការពិសោធន៍វិទ្យាសាស្ត្រដែលពួកគេស្រាវជ្រាវក្នុងពេលពិព័រណ៍ក្នុងខេត្តទាំងបី (រូបភាពខាងឆ្វេង)*